ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារជូនពរ

**សូមគោរពជូន**

**សម្ដេចក្រឡាហោម ស ខេង ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៤**

***សម្ដេចក្រឡាហោម ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !***

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្ដីសោមនស្សរីករាយ ក្នុងទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៤ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំបាទនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្ដី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្ដេចក្រឡាហោម** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន ខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសនេះដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្ដែងនូវសេចក្ដីគោរពដ៏ស្មោះស្ម័គ្រ និងកោតសរសើរយ៉ាងក្រៃលែងនូវការដឹកនាំរបស់ **សម្ដេច** ដែលកន្លងមកតែងបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយនិងប្រាជ្ញាស្មារតី ជាមួយនឹងបទពិសោធន៍ដ៏ប៉ិនប្រសប់ប្រកបដោយគំរូវីរភាពដ៏មោះមុតសម្រេចបាននូវស្នាដៃ និងសមិទ្ធផលជាច្រើនគួរឱ្យស្ញប់ស្ញែងជាបន្តបន្ទាប់។ ជាពិសេសទប់ស្កាត់បាននូវសកម្មភាពភេរវកម្មគ្រប់ប្រភេទ ព្រមទាំងរក្សាបាននូវ សន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសង្គមបានយ៉ាងរឹងមាំ ធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពកក់ក្ដៅ និងមានទំនុកចិត្តជាខ្លាំងលើរាជរដ្ឋាភិបាលកម្ពុជា និងធ្វើឱ្យប្រទេសជាតិមានស្ថិរភាព សុវត្ថិភាព និងសុខសន្តិភាពសម្បូរសប្បាយរុងរឿង។

ជាថ្មីម្ដងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំបាទនិងភរិយា សូមបួងសួងដល់វត្ថុស័ក្ដិសិទ្ធិទាំងឡាយក្នុងលោក ទេវតាឆ្នាំថ្មី ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល ជូន **សម្ដេចក្រឡាហោម** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចក្រឡាហោម ស ខេង ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

ថ្ងៃសុក្រ ២ រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្ដមសេនីយ៍ ទៀ សីហា**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៧៨: generalsec@mod.gov.kh